ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២៣ សរុបមានចំនួន៣៩ ៤៩០,៤ លានរៀល ក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាល៖** បានគ្រោងចំណូលសរុបចំនួន៣៩ ៤៨៩ លានរៀល ចំណូលនេះរួមមាន ៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២២ ៩០៧ លានរៀល ស្មើនឹង៥៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន១៤ ៧៨២ លានរៀល ស្មើនឹង៣៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន១ ៨០០ លានរៀល ស្មើនឹង៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

**(ខ)-មន្ទីររាជធានី ខេត្ត៖** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការជួលដីទំនេរ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូលសរុបមានចំនួន៧ ៧២៩,១ លានរៀល ស្មើនឹង១៩,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៨២,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាល៖** អនុវត្តប្រមូលចំណូលសរុបចំនួន ៧ ៧២៩,១ លានរៀល ស្មើនឹង១៩,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៨២,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២ ៤២១,៤ លានរៀល ស្មើនឹង១០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៥២,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន៤ ៨៨២,២ លានរៀល ស្មើនឹង៣៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១១៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន៣៦៤,៧ លានរៀល ស្មើនឹង២០,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៦៧,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤)ផលហិរញ្ញវត្ថុ មានចំនួន៦០,៩ លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយបៀវត្ស។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

(ខ)-**មន្ទីររាជធានី ខេត្ត៖** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺមិនទាន់បានអនុវត្តចំណូលពីការជួលដីទំនេរទេ។

**II-ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុប៨ ៤៨០,៣ លានរៀល។ បន្តអនុវត្តកិច្ចសម្របសម្រួល និងសហការជាមួយអង្គភាពប្រមូលចំណូល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំប្រកាសអន្តរក្រសួង និងឯកសារកែសម្រួលសេវាសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**III-សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលល្អប្រសើរទោះបីមិនបាន១០០% ធៀបទៅនឹងកម្មវិធីដែលបានដាក់ចេញក៏ដោយ។ ករណីនេះបណ្តាលមកពីការអនុវត្តចំណូលសួយសារកូនឈើ និងការចេញលិខិតអនុញ្ញាតរដ្ឋបាល របស់រដ្ឋបាលព្រៃឈើ អនុវត្តបានតិច (ប្រមាណជា២៥%) ម្យ៉ាងទៀតការលក់សម្ភារខូចខាត ឯកសារលតាប័ត្រ លិខិតបោះពុម្ពផ្សេងៗ និងការលក់ផលិតផលកសិកម្មមិនទាន់បានអនុវត្តនៅឡើយ។ ទន្ទឹមនេះចំណូលពីការត្រួតពិនិត្យអនាម័យសត្វ និងការជាកពិន័យផ្សេងៗ អនុវត្តបាន ក្នុងកម្រិតមធ្យមនៃកម្មវិធីដែលបានដាក់ចេញ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឱ្យបានតាមផែនការឆ្នាំ២០២៣ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឱ្យបានទាន់ពេលវេលា គួបផ្សំនឹងប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ថ្ងៃសុក្រ ០៩ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត សេង គឹមស៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្ដីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សេចក្ដីផ្ដើម

ឆ្នាំ២០២៣ គឺជាឆ្នាំទី៨ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ៖ "**ជំរុញកំណើនកសិកម្មតាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្ម ពិពិធកម្មកសិកម្ម និងជំរុញឌីជីថលូបនីយកម្មប្រកបដោយភាពប្រកួតប្រជែង បរិយាប័ន្ន ដែលផ្ដល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល**"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្ដាលមានចំនួន២១ អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២៥ រាជធានី ខេត្ត។

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណាយឆ្នាំ២០២៣ សរុបមានចំនួន២៨០ ៧៦៨ លានរៀល ក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្ដាល៖** បានគ្រោងឥណទានចំណាយសរុបចំនួន១៧៩ ១៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ១៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៥ ០០០ លានរៀល

**(ខ)-មន្ទីររាជធានី ខេត្ត ៖** បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន១០១ ៥៩១ លានរៀល។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី១ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ អនុវត្តចំណាយតាមអាណត្តិបើកប្រាក់សរុបចំនួន៤៧ ៧៦៨,៥ លានរៀល ស្មើនឹង១៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ក្នុងនោះរដ្ឋបាលកណ្ដាលអនុវត្តបានចំនួន២៩ ៤៤២,១ លានរៀល ស្មើនឹង១៦,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៨០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ រីឯមន្ទីររាជធានី ខេត្ត អនុវត្តបានចំនួន ១៨ ៣២៦,៤ លានរៀល ស្មើនឹង១៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៧៩,៦% ធៀបនឹងកម្មវិធី ដែលបានដាក់ចេញ។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

(**ក**)-**រដ្ឋបាលកណ្តាល៖**

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១ អង្គភាពថវិកា) សម្រេចបានចំនួន២៩ ៤៤២,១ លានរៀល ដោយក្នុងនោះ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ៥៨៩,១ លានរៀល ស្មើនឹង៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៣៤,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន១ ២០៩,៩ លានរៀល ស្មើនឹង៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១៩,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១៦ ៣០៨,៤ លានរៀល ស្មើនឹង២០,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៨១,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន១០ ៣៣៤,៧ លានរៀល ស្មើនឹង៤២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១៦៩,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ចំណាយមូលធន (ជំពូក២១) មិនទាន់បានអនុវត្តនៅឡើយ។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន២៩ ៤៤២,១ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់ ៖

(១) ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច (កម្មវិធីទី១) ចំនួន៣ ៥០៧,១ លានរៀល ស្មើនឹង៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(២) ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ (កម្មវិធីទី២) ចំនួន៨៨៧,៥ លានរៀល ស្មើនឹង៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៣) ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន១ ០៥៤,៧ លានរៀល ស្មើនឹង៩,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៤) ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ (កម្មវិធីទី៤) ចំនួន៤៦៧,៥ លានរៀល ស្មើនឹង ៥,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៥) ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស (កម្មវិធីទី៥) ចំនួន២៣ ៥២៥,៣ លានរៀល ស្មើនឹង២២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

(**ខ**)-**មន្ទីររាជធានី ខេត្ត ៖**

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន១៨ ៣២៦,៤ លានរៀល គឺអនុវត្តលើសឆ្នាំ២០២២ ក្នុងរយៈពេលដូចគ្នាប្រមាណ៣% ក្នុងនោះចំណាយលើ (ក) ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ៣៨៨,៣ លានរៀល ស្មើនឹង១២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៤៦,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន២ ៣៩០,៩ លានរៀល ស្មើនឹង១០,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៦១,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១៣ ៥៧៧,៥ លានរៀល ស្មើនឹង២២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ៩២,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)អត្ថប្រយោជន៍សង្គម អនុវត្តបានចំនួន៩៦៩,៧ លានរៀល ស្មើនឹង១៣,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៦៤,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) មិនទាន់បានអនុវត្តនៅឡើយនៅក្នុងត្រីមាសទី១ នេះ។

ម្យ៉ាងទៀត ដោយពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុបចំនួន១៨ ៣២៦,៤ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដូចខាងក្រោម៖

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣ | កម្មវិធី ត្រីមាសទី១ | ការអនុវត្ត ត្រីមាសទី១ | %អនុ.ត្រីមាសទី១ ធៀបច្ប.២០២៣ | %ធៀបកម្មវិធី ត្រីមាសទី១ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | 4,080,300,000 | 1,284,888,000 | 646,931,675 | 15.9% | 50.3% |
| បាត់ដំបង | 6,657,000,000 | 1,651,699,000 | 1,649,770,590 | 24.8% | 99.9% |
| កំពង់ចាម | 4,252,700,000 | 1,033,830,000 | 760,972,050 | 17.9% | 73.6% |
| កំពង់ឆ្នាំង | 4,512,200,000 | 1,017,400,000 | 953,753,400 | 21.1% | 93.7% |
| កំពង់ស្ពឺ | 4,791,000,000 | 917,200,000 | 827,553,770 | 17.3% | 90.2% |
| កំពង់ធំ | 5,685,000,000 | 1,454,925,000 | 1,065,229,600 | 18.7% | 73.2% |
| កំពត | 4,326,700,000 | 879,000,000 | 723,177,010 | 16.7% | 82.3% |
| កណ្តាល | 6,516,000,000 | 1,697,160,000 | 1,621,587,500 | 24.9% | 95.5% |
| កោះកុង | 2,628,600,000 | 578,310,000 | 333,231,171 | 12.7% | 57.6% |
| ក្រចេះ | 3,902,000,000 | 1,026,000,000 | 920,164,588 | 23.6% | 89.7% |
| មណ្ឌលគិរី | 2,718,700,000 | 479,300,000 | 317,214,000 | 11.7% | 66.2% |
| រាជធានីភ្នំពេញ | 4,193,600,000 | 976,300,000 | 891,123,770 | 21.2% | 91.3% |
| ព្រះវិហារ | 2,795,900,000 | 502,400,000 | 466,836,300 | 16.7% | 92.9% |
| ព្រៃវែង | 4,509,200,000 | 732,927,000 | 535,462,142 | 11.9% | 73.1% |
| ពោធិ៍សាត់ | 3,993,400,000 | 1,320,110,000 | 623,662,500 | 15.6% | 47.2% |
| រតនគិរី | 3,112,900,000 | 415,500,000 | 598,849,929 | 19.2% | 144.1% |
| សៀមរាប | 5,797,500,000 | 1,117,248,000 | 701,604,100 | 12.1% | 62.8% |
| ព្រះសីហនុ | 2,968,900,000 | 645,000,000 | 427,353,820 | 14.4% | 66.3% |
| ស្ទឹងត្រែង | 3,427,100,000 | 416,000,000 | 438,007,500 | 12.8% | 105.3% |
| ស្វាយរៀង | 3,195,600,000 | 509,100,000 | 451,981,850 | 14.1% | 88.8% |
| តាកែវ | 6,215,300,000 | 1,553,475,000 | 1,058,226,360 | 17.0% | 68.1% |
| ឧត្តរមានជ័យ | 3,371,800,000 | 1,273,421,000 | 1,173,560,000 | 34.8% | 92.2% |
| កែប | 1,692,500,000 | 378,500,000 | 276,793,630 | 16.4% | 73.1% |
| ប៉ៃលិន | 2,217,900,000 | 436,500,000 | 384,443,597 | 17.3% | 88.1% |
| ត្បូងឃ្មុំ | 4,029,200,000 | 728,900,000 | 478,877,390 | 11.9% | 65.7% |

III-**បញ្ហាប្រឈម**

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ សម្រេចបានខ្ពស់ជាងត្រីមាសទី១ ឆ្នាំ២០២២ ប្រមាណ២% ដោយសារអង្គភាពថវិកាទាំងអស់អនុវត្តយល់ដឹងតាមប្រកាស សារាចរណែនាំ និងនីតិវិធីថ្មីៗ បានដាក់ចេញនាពេលកន្លងមក។

ទន្ទឹមនឹងនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធន ដែលបញ្ហាលំបាកទាំងនោះមានដូចជា ៖

- ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវប្រើពេលវេលាយូរ
- ការអនុវត្តកិច្ចលទ្ធកម្មមានច្រើនដំណាក់កាលប្រើពេលវេលាយូរធ្វើឱ្យយឺតយ៉ាវក្នុងការទទួលបានសម្ភារ ឧបករណ៍

ផ្សេងៗ យកមកអនុវត្តសកម្មភាពការងារ

- ការផ្តល់បុរេប្រទានជូន៦០% នៃសំណើសុំ ធ្វើឱ្យមានការលំបាករកថវិកា៤០% ពីប្រភពផ្សេងយកមកធ្វើសកម្មភាព ការផ្តល់នេះមិនឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់ការងារ។

IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន៣៩ ៩៨៧ លានរៀល ក្នុងនោះ (១)រដ្ឋបាលកណ្តាល ចំនួន៣៥ ២៤៦,៣ លានរៀល (២) មន្ទីររាជធានី-ខេត្ត ចំនួន៤ ៧៤០,៧ លានរៀល។

V-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលល្អប្រហាក់ប្រហែលនឹងចំណាយប្រចាំត្រីមាសទី១ ឆ្នាំ២០២២។

ថ្ងៃសុក្រ ០៩ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត សេង គឹមស៊ុន**